ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១១៧៧ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋានរបស់យន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬ ទណ្ឌកម្ម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានយន្តការថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៧/០០២ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគី នៃពិធីសារបន្ថែម នៃអនុសញ្ញាស្តីពីការប្រឆាំងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- បានឃើញអនុក្រឹត្យ លេខ ១២២ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតយន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម
- យោងតាមការចាំបាច់របស់យន្តការទប់ស្កាត់ថ្នាក់ជាតិ

## សម្រេច

### ប្រការ ១ .-

ត្រូវបានបង្កើតលេខាធិការដ្ឋានមួយ ជាសេនាធិការឱ្យយន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដែលហៅកាត់ថា "លេខាធិការដ្ឋានយន្តការទប់ស្កាត់ថ្នាក់ជាតិ" ដែលមានទីស្នាក់ការអចិន្ត្រៃយ៍នៅក្នុងបរិវេណក្រសួងមហាផ្ទៃ ។

**ប្រការ ២ .-**

លេខាធិការដ្ឋានយន្តការទប់ស្កាត់ថ្នាក់ជាតិនេះ ត្រូវបានរៀបចំមន្ត្រីដែលមានក្របខ័ណ្ឌស្រាប់ពីក្រសួង ស្ថាប័នជាសមាជិកក្នុងយន្តការថ្នាក់ជាតិនេះ ដើម្បីបំពេញភារកិច្ច ដែលមានសមាសភាព ដូចខាងក្រោម ÷

១-លោក **នុត សវនា** សមាជិកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ ជាប្រធានលេខាធិការដ្ឋាន

២-លោក **កែវ វិសិដ្ឋ** ប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអនុប្រធាន

៣-លោក **សួរ ឌីម៉ា** សមាជិកក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ ជាសមាជិក

៤-លោក **ប៊ុង ណាល់** ប្រធាននាយកដ្ឋានយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក

៥-លោក **សរ ភមរ៉ា** ប្រធាននាយកដ្ឋានកិច្ចការអយ្យការ នៃក្រសួងយុត្តិធម៌ ជាសមាជិក

៦-លោក **គីម ជួន** អនុប្រធាននាយកដ្ឋានប្រតិបត្តិ នៃអគ្គនាយកដ្ឋានពន្ធនាគារ ជាសមាជិក

៧-លោកវរសេនីយ៍ត្រី **ផេង គីមស្រ៊ុន** ប្រធានការិយាល័យរដ្ឋបាល-សរុប នៃលេខាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម ជាសមាជិក

៨-លោកវេជ្ជបណ្ឌិត **គីម សាវួន** ប្រធានការិយាល័យសុខភាពផ្លូវចិត្តនៃក្រសួងសុខាភិបាល ជាសមាជិក

៩-លោកវរសេនីយ៍ទោ **លី ហ៊ាង** នាយរងការិយាល័យស៊ើបការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជាសមាជិក

១០-លោកវរសេនីយ៍ទោ **ស្វាយ សុធា** នាយរងការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិក

១១-លោកអនុសេនីយ៍ត្រី **សារ៉ាត ពិសិដ្ឋ** មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ជាសមាជិក

១២-លោក **អ៊ិត សាន** មន្ត្រី នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាសមាជិក

**ប្រការ ៣ .-**

លេខាធិការដ្ឋានយន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ត្រូវបំពេញភារកិច្ច ដូចខាងក្រោម ÷

**ក-ការងារប្រតិបត្តិ**

ការងារប្រតិបត្តិ រួមជាមួយសមាជិកយន្តការថ្នាក់ជាតិ មានដូចខាងក្រោម ÷

-ទទួលពាក្យបណ្តឹងពីការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ពីគ្រប់ទីកន្លែង

-រៀបចំក្រុមការងារអចិន្ត្រៃយ៍ ទទួលខុសត្រូវតាមទីកន្លែងបំបិទសិទ្ធិសេរីភាព ដោយធ្វើការសម្របសម្រួល

ជាមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិ ជាមុន

-ចុះត្រួតពិនិត្យដល់ទីកន្លែងកើតហេតុភ្លាម ឬ ករណីទទួលព័ត៌មានថាមានការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

-បង្កើតប្រអប់សំបុត្រ ដើម្បីឱ្យប្រជាពលរដ្ឋ ឬមហាជននានា អាចផ្តល់ព័ត៌មានដោយសម្ងាត់

-រៀបចំប្រព័ន្ធទូរស័ព្ទរហ័ស (HOT LINE) ដើម្បីទទួលបានព័ត៌មានពីការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

-ធ្វើសេចក្តីរាយការណ៍ជូនប្រធានយន្តការទប់ស្កាត់ថ្នាក់ជាតិ ពីមន្ត្រីពាក់ព័ន្ធនឹងការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីចាត់វិធានការសមស្របនានា។

**ខ_ការងាររដ្ឋបាល និងទំនាក់ទំនង**

ការងាររដ្ឋបាល និងទំនាក់ទំនង រួមជាមួយសមាជិកយន្តការថ្នាក់ជាតិ មានដូចខាងក្រោម ÷

-សម្របសម្រួលសវនាការរវាងប្រធាន និងថ្នាក់ដឹកនាំយន្តការទប់ស្កាត់ថ្នាក់ជាតិជាមួយដៃគូអភិវឌ្ឍន៍លើការទប់ស្កាត់ និងបង្ការអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

-សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ក្នុងយន្តការទប់ស្កាត់ថ្នាក់ជាតិ និងដៃគូអភិវឌ្ឍន៍នានាលើការងារទប់ស្កាត់ និងបង្ការអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម

-រៀបចំលិខិតអញ្ជើញប្រជុំ និងបូកសរុបរបាយការណ៍ ជូនប្រធានយន្តការទប់ស្កាត់ថ្នាក់ជាតិ និងក្រសួង ស្ថាប័ន ក្នុងយន្តការថ្នាក់ជាតិ

-រៀបចំលិខិតបេសកកម្ម និងមធ្យោបាយនានាដល់ក្រុមការងារពេលចុះបំពេញបេសកកម្ម។

**គ_ការងាររៀបចំប្រព័ន្ធទិន្នន័យ**

ការងាររៀបចំប្រព័ន្ធទិន្នន័យ រួមជាមួយសមាជិកយន្តការថ្នាក់ជាតិ មានដូចខាងក្រោម ÷

-បង្កើតប្រព័ន្ធ Internet - E-mail

-បញ្ចូលព័ត៌មានពាក់ព័ន្ធការងារទប់ស្កាត់ និងបង្ការអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ទៅក្នុងប្រព័ន្ធកុំព្យូទ័រ

-ប្រមូលនិងវិភាគទិន្នន័យពាក់ព័ន្ធការងារទប់ស្កាត់ និងបង្ការអំពើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។

**ប្រការ ៤ ._**

គ្រប់ការងារ និងសំណើផ្សេងៗ ត្រូវមានយោបល់របស់ប្រធានលេខាធិការដ្ឋាន និងអនុប្រធានអចិន្ត្រៃយ៍យន្តការថ្នាក់ជាតិដើម្បីដាក់ជូនប្រធានយន្តការថ្នាក់ជាតិ ពិនិត្យ និងសម្រេច។

**ប្រការ ៥ ._**

យន្តការទប់ស្កាត់ថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខ

បុកម្មេញ ឬទណ្ឌកម្ម អាចបំពេញភារកិច្ចរបស់ខ្លួនមានប្រសិទ្ធភាព ចាំបាច់ត្រូវមាន ÷

-ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ

-សម្ភារៈ មធ្យោបាយ និងទីកន្លែងធ្វើការ

-ការឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍នានាទាំងខាងថវិកា សម្ភារៈ និងមធ្យោបាយនានា ។

**ប្រការ ៦ ._**

ថវិកាសម្រាប់បុព្វហេតុរដ្ឋបាល សម្ភារៈការិយាល័យ ថវិកាសម្រាប់បេសកកម្ម និងការចំណាយផ្សេងៗសម្រាប់ដំណើរការការងាររបស់លេខាធិការដ្ឋាននៃយន្តការទប់ស្កាត់ថ្នាក់ជាតិត្រូវស្ថិតក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៧ ._**

ប្រាក់បៀវត្សរ៍ ប្រាក់គុណបំណាច់ផ្សេងៗ ត្រូវរក្សានៅអង្គភាពដើមដដែល ។

ការផ្លាស់ប្តូរ ការដកហូតតំណែង ឬការតម្លើងឋានន្តរសក្តិរបស់ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋានរបស់យន្តការថ្នាក់ជាតិ ត្រូវធ្វើឡើងពីអង្គភាពសាមី ដោយមានការយល់ព្រមពីប្រធានយន្តការថ្នាក់ជាតិ ។

**ប្រការ ៨ ._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ ._**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងប្រធានយន្តការថ្នាក់ជាតិ**

ស ខេង

**កន្លែងទទួល :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ក្រសួងព្រះបរមរាជវាំង
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ៩
-ឯកសារ-កាលប្បវត្តិ